ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តតាកែវ

សំណុំរឿងរដ្ឋប្បវេណីលេខៈ ១៧៨
ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០
សាលក្រមរដ្ឋប្បវេណី លេខៈ ១២(គ)
ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣

# សាលក្រម
## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តតាកែវ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់
នៅថ្ងៃចន្ទ ១០កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣
និង ប្រកាសសាលក្រមជាសាធារណៈ
នៅថ្ងៃចន្ទ ៩កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣

**ចៅក្រមជំនុំជម្រះ**

លោក [redacted] អនុប្រធាន និងជាចៅក្រម សាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជី សាលាដំបូងខេត្តតាកែវ

**ដើមចោទៈ** ឈ្មោះ [redacted] **ថាវឿន** ភេទស្រី អាយុ៤៦ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅ [redacted] ។

ដោយមានលោក [redacted] អត្តលេខ ៩១៦ ជាមេធាវីនៅការិយាល័យមេធាវី [redacted] និងជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] ថាវឿន។

**សហចុងចម្លើយៈ** ឈ្មោះ [redacted] **សម្បត្តិ** ភេទប្រុស អាយុ៣៥ឆ្នាំ សញ្ជាតិខ្មែរ និងប្រពន្ធឈ្មោះ [redacted] **រីណា** ភេទស្រី អាយុ៣៣ មានអាសយដ្ឋាន [redacted]

ដោយមានលោក [redacted] អត្តលេខ ៦១៣ និងលោក [redacted] អត្តលេខ ១២០៧ និងលោក [redacted] អត្តលេខ ២៧០៨T ជាមេធាវី មានការិយាល័យស្ថិតនៅ [redacted] និងជាមេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយឈ្មោះ [redacted] សម្បត្តិ និងឈ្មោះ [redacted] រីណា។

## អង្គហេតុ និងចំណុចវិវាទ

**១-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ ៖**

ក-បង្គាប់ឱ្យសហចុងចម្លើយសងប្រាក់ដើម ចំនួន ៥៥.៦៥០.០០០(ហាសិបប្រាំលានប្រាំមួយសែនប្រាំម៉ឺន)រៀល ឱ្យទៅដើមចោទ។



Scanned with CamScanner

ខ-បង្គាប់ឱ្យសហចុងចម្លើយសងការប្រាក់ ចំនួន ៩៧៤ (ប្រាំបួនរយចិតសិបបួន)ដុល្លារអាមេរិក ក្នុងមួយខែ គិតពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងគ្រប់ចំនួន ឱ្យទៅដើមចោទ។

គ-បង្គាប់ឱ្យសហចុងចម្លើយសងសំណងការខូចខាតលើសេវាកម្មច្បាប់ និងជំងឺចិត្ត ចំនួន **២០.០០០.០០០**(**ម្ភៃលាន**)**រៀល**។

ឃ-សុំអនុវត្តសាលក្រមជាបណ្តោះអាសន្នលើប្រាក់ដើម ចំនួន **៥៥.៦៥០.០០០ (ហាសិបប្រាំលានប្រាំមួយសែនប្រាំម៉ឺន)រៀល**។

**២-ពន្យល់ត្រួសៗអំពីអង្គហេតុ**

កាលពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៨ សហចុងចម្លើយឈ្មោះ [redacted]សម្បត្តិ និងឈ្មោះ [redacted]ណា បានខ្ចីប្រាក់ពីដើមចោទឈ្មោះ [redacted]ថាវឿន ចំនួន ៥០.០០០.០០០(ហាសិបលាន)រៀល គិតការប្រាក់ ចំនួន ៨៧៥ (ប្រាំបីរយចិតសិបប្រាំ) ដុល្លារអាមេរិក ក្នុងមួយខែ ដោយបានធ្វើកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ដាក់បញ្ចាំដី ដែលមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី លេខ៩៨៩/១៨ ប.ជ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៨ និង ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី លេខ៩៩០/១៨ ប.ជ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៨។ ថ្ងៃខែឆ្នាំដដែល សហចុងចម្លើយឈ្មោះ [redacted]សម្បត្តិ និងឈ្មោះ [redacted] វីណា បានខ្ចី ប្រាក់ពីដើមចោទឈ្មោះ [redacted]ថាវឿន បន្ថែម ចំនួន ៥.៦៥០.០០០(ប្រាំលានប្រាំមួយសែនប្រាំម៉ឺន)រៀល ដោយមានការប្រាក់ ៩៩(កៅសិបប្រាំបួន)ដុល្លារអាមេរិក ក្នុងមួយខែ ដោយបានធ្វើកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ដាក់បញ្ចាំដី ដែលមានកិច្ចសន្យាលក់ដីភូមិ លេខ ២៥៤/១៧ ចុះថ្ងៃទី០៦ ខែ១២ ឆ្នាំ ២០១៧។ សហចុងចម្លើយ សន្យាសងប្រាក់ដើមចោទវិញនៅ ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩។ កាលបរិច្ឆេទសងបានកន្លងហួសជាយូរមកហើយ សហចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា ទោះជាដើមចោទបានទាមទារនិងដាស់តឿន ជាច្រើនដងក៏នៅតែមិនព្រមសង។ ទើបដើមចោទដាក់ពាក្យបណ្តឹងចូលមកតុលាការតែម្តង។

**៣-ការអះអាងរបស់គូភាគី**

**៣.១.ការអះអាងរបស់ដើមចោទ៖**

ដើមចោទឈ្មោះ [redacted]ថាវឿន បានធ្វើសេចក្តីថ្លែងការណ៍ ខ្លួនសុំឱ្យតុលាការចេញសាលក្រមសម្រេចដូចក្រោម៖

ក-បង្គាប់ឱ្យសហចុងចម្លើយសងប្រាក់ដើម ចំនួន ៥៥.៦៥០.០០០(ហាសិបប្រាំលានប្រាំមួយសែនប្រាំម៉ឺន)រៀល ឱ្យទៅដើមចោទ។

ខ-បង្គាប់ឱ្យសហចុងចម្លើយសងការប្រាក់ ចំនួន ៩៧៤ (ប្រាំបួនរយចិតសិបបួន)ដុល្លារអាមេរិក ក្នុងមួយខែ គិតពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងគ្រប់ចំនួនឱ្យទៅដើមចោទ។

គ-បង្គាប់ឱ្យសហចុងចម្លើយសងសំណងការខូចខាតលើសេវាកម្មច្បាប់ និងជំងឺចិត្ត ចំនួន ២០.០០០.០០០(ម្ភៃលាន)រៀល។

ឃ-សុំអនុវត្តសាលក្រមជាបណ្តោះអាសន្នលើប្រាក់ដើម ចំនួន ៥៥.៦៥០.០០០ (ហាសិបប្រាំលានប្រាំមួយសែនប្រាំម៉ឺន)រៀល។



Scanned with CamScanner

មូលហេតុដែលខ្លួនទាមទារប្រាក់ពីសហចុងចម្លើយ ព្រោះលើកទី១ កាលពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៨ សហចុងចម្លើយឈ្មោះ [redacted] សម្បត្តិ និងឈ្មោះ [redacted]រីណា បានខ្ចីប្រាក់ពីខ្លួន ចំនួន ៥០.០០០.០០០(ហាសិបលាន)រៀល គិតការប្រាក់ចំនួន ៨៧៥ (ប្រាំបីរយចិតសិបប្រាំ)ដុល្លារអាមេរិក ក្នុងមួយខែ ដោយបានធ្វើកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ដាក់បញ្ចាំដី ដែលមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី លេខ ៩៨៩/១៨ ប.ជ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៨ និងពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ៩៩០/១៨ ប.ជ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៨។ លើកទី២ ថ្ងៃខែឆ្នាំដដែល សហចុងចម្លើយឈ្មោះ [redacted] សម្បត្តិ និងឈ្មោះ [redacted]រីណា បានខ្ចីប្រាក់ពីខ្លួនបន្ថែម ចំនួន ៥.៦៥០.០០០(ប្រាំលានប្រាំមួយសែនប្រាំម៉ឺន)រៀល ដោយមានការប្រាក់ ៩៩(កៅសិបប្រាំបួន)ដុល្លារអាមេរិក ក្នុងមួយខែ ដោយបានធ្វើកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ដាក់បញ្ចាំដី ដែលមានកិច្ចសន្យាលក់ដីភូមិ លេខ ២៥៤/១៧ ចុះថ្ងៃទី០៦ ខែ១២ ឆ្នាំ២០១៧។ សហចុងចម្លើយខ្ចីប្រាក់ពីខ្លួនទាំង ២លើក សន្យាសងនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩។ កាលបរិច្ឆេទសងបានកន្លងហួស ជាយូរមកហើយ សហចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាទោះជាដើមចោទបានទាមទារ និងដាស់តឿន ជាច្រើនដងក៏នៅតែមិនព្រមសង។ ការបំពានកិច្ចសន្យារបស់សហចុងចម្លើយ បានធ្វើឱ្យខូចប្រយោជន៍ស្របច្បាប់របស់ដើមចោទ និងការខាតបង់លើសេវាកម្មផ្លូវច្បាប់ និងផ្លូវចិត្តផងដែរ។

**៣.២.សេចក្តីថ្លែងការរបស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted]ជាវឿន៖**

លោក [redacted] ធ្វើសេចក្តីថ្លែងការណ៍៖ ខ្លួនឯកភាពនឹងសេចក្តីថ្លែងការរបស់ដើមចោទ និងសុំបន្ថែមថា ទោះបីជាចុងចម្លើយបានបដិសេធកិច្ចសន្យាក៏ដោយ ក៏កិច្ចសន្យានេះមានការបញ្ជាក់ពីមេភូមិ និងមេឃុំ និងមានសាក្សីដឹងឮ។ ការបដិសេធរបស់ចុងចម្លើយ គឺមិនសមហេតុសមផលនោះទេ ព្រោះចុងចម្លើយអ្នកមានចំណេះដឹង ហើយជាអ្នកមានមុខជំនួញធំ គឺមិនអាចផ្តិតមេដៃលើក្រដាសសនោះទេ។ ខ្លួនស្នើសុំឱ្យតុលាការសម្រេចតាមភស្តុតាងមានក្នុងសំណុំរឿង។

**៣.៣.ការអះអាងរបស់ចុងចម្លើយ៖**

ចុងចម្លើយឈ្មោះ [redacted]រីណា បានធ្វើសេចក្តីថ្លែងការណ៍តប៖ ការផ្តិតមេដៃគ្រាន់តែបញ្ជាក់អំពីម្ចាស់កម្មសិទ្ធិនៃដីតែប៉ុណ្ណោះ។ ចំនួនទឹកប្រាក់ដែលខ្លួនខ្ចីដើមចោទត្រឹមតែ ៩.០០០(ប្រាំបួនពាន់)ដុល្លារអាមេរិក។

**៣.៤.សេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយឈ្មោះ [redacted]សម្បត្តិ និងឈ្មោះ [redacted]រីណា៖**

លោក [redacted]បានធ្វើសេចក្តីថ្លែងការណ៍តប៖ កូនក្តីខ្លួននៅតែមិនទទួលស្គាល់កិច្ចសន្យាទាំង ២ នោះទេ គឺទទួលស្គាល់ប្រាក់ដែលជំពាក់ត្រឹមតែចំនួន ៩.០០០(ប្រាំបួនពាន់)ដុល្លារអាមេរិក។ ខ្លួនសុំឱ្យតុលាការពិចារណាលើមាត្រា ៣៥១ លើការប្រាក់ដែលចំណេញហួសហេតុពេក។

**៣.៥.តាមចម្លើយរបស់សាក្សីឈ្មោះ [redacted]៖**

លោក [redacted]មេឃុំ បានឆ្លើយថា៖ ចំពោះកិច្ចសន្យាគូភាគីបានធ្វើរួច ទើបយកមកជូនខ្លួនបញ្ជាក់តាមក្រោយ។

**៣.៦.តាមចម្លើយរបស់សាក្សីឈ្មោះ [redacted]៖**

លោក [redacted] មេភូមិ បានឆ្លើយថា៖ ចំពោះកិច្ចសន្យាគឺ គូភាគីជាអ្នកធ្វើខ្លួនឯង ខ្លួនគ្រាន់តែបញ្ជាក់អំពីដីដែលយកមកបញ្ចាំជាកម្មសិទ្ធិរបស់ចុងចម្លើយ។

**៤-ការពិនិត្យភស្តុតាង**

-កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨។

-កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨។

-ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី លេខ៩៨៩/១៨ ប.ជ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៨។

-ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី លេខ៩៩០/១៨ ប.ជ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៨។

-កិច្ចសន្យាលក់ដីភូមិ លេខ ២៥៤/១៧ ចុះថ្ងៃទី០៦ ខែ១២ ឆ្នាំ ២០១៧។

**៥-ចំណុចគ្មានវិវាទ និងចំណុចវិវាទ៖**

**ចំណុចគ្មានវិវាទ-គ្មាន។**

**ចំណុចវិវាទ៖**

-តើសហចុងចម្លើយជំពាក់ប្រាក់ដើមចោទ ចំនួន **៥៥.៦៥០.០០០**(ហាសិបប្រាំលានប្រាំមួយសែនប្រាំម៉ឺន)រៀល មែន ឬទេ?

-តើដើមចោទទាមទារការប្រាក់ដើមចោទ ចំនួន **៩៧៤(ប្រាំបួនរយចិតសិបបួន)ដុល្លារអាមេរិក** ក្នុងមួយខែ គិតពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងគ្រប់ចំនួន ត្រឹមត្រូវតាមច្បាប់ ឬទេ?

-តើដើមចោទរងការខូចខាតលើសេវាកម្មច្បាប់ និងជំងឺចិត្ត ចំនួន **២០.០០០.០០០(ម្ភៃលាន)រៀល** មែន ឬទេ?

-តើត្រូវអនុវត្តសាលក្រមជាបណ្តោះអាសន្នលើប្រាក់ដើម ចំនួន **៥៥.៦៥០.០០០**(ហាសិបប្រាំលានប្រាំមួយសែនប្រាំម៉ឺន)រៀល ឬទេ?

**សំអាងហេតុ**

យោងតាមលទ្ធផលនៃការសាកសួរ ការអះអាងរបស់ភាគី និងការពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ **យល់ឃើញថា៖**

១.ពាក្យបណ្តឹង ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ របស់ដើមចោទឈ្មោះ [redacted] **ថារឿន** មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ដែលអាចឱ្យតុលាការលើកមកដោះស្រាយ ចេញសេចក្តីសម្រេចជាសាលក្រមបាន ដោយអនុលោមតាមបញ្ញត្តិមាត្រា ៧៤ និងមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២.តាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ រវាងឈ្មោះ [redacted] ថារឿន និងឈ្មោះ [redacted] សម្បត្តិ និងឈ្មោះ [redacted] វីណា **ឃើញថា** ដើមចោទឈ្មោះ [redacted] ថារឿន បានឱ្យសហចុងចម្លើយឈ្មោះ [redacted] សម្បត្តិ និង ឈ្មោះ [redacted] វីណា ខ្ចីប្រាក់ចំនួន **៥០.០០០.០០០ (ហាសិបលាន)រៀល** និងភ្ជាប់នឹងការប្រាក់ ៨៧៥ (ប្រាំបីរយចិតសិបប្រាំ)ដុល្លារអាមេរិក ក្នុងមួយខែ ដោយគិតចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៨ ដល់ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ និងតាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ រវាងឈ្មោះ [redacted] ថារឿន និងឈ្មោះ [redacted] សម្បត្តិ និងឈ្មោះ [redacted] វីណា ឃើញថា ដើមចោទឈ្មោះ [redacted] ថារឿន បានឱ្យសហចុងចម្លើយឈ្មោះ [redacted] សម្បត្តិ និងឈ្មោះ [redacted] វីណា ខ្ចីប្រាក់ចំនួន **៥.៦៥០.០០០**(ប្រាំលានប្រាំមួយសែនប្រាំម៉ឺន)រៀល និងភ្ជាប់នឹងការប្រាក់ ៩៩ (កៅសិបប្រាំបួន)ដុល្លារអាមេរិក ក្នុងមួយខែ ដោយ



Scanned with CamScanner

គិតចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៨ ដល់ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩។ ប៉ុន្តែ តាមសេចក្តីថ្លែងការណ៍របស់ចុងចម្លើយឈ្មោះ [redacted]រីណា បានបញ្ជាក់ថាខ្លួនបានចុះកិច្ចសន្យាទី១ តែប៉ុណ្ណោះ ដែលមានទឹកប្រាក់ត្រឹមតែចំនួន ៩.០០០(ប្រាំបួនពាន់)ដុល្លារអាមេរិក។ ដោយឡែកកិច្ចសន្យាទី២ ខ្លួនសុំបដិសេធចំពោះកិច្ចសន្យាទី២ គឺផ្តិតមេដៃលើក្រដាសសនោះទេ។ គប្បីតុលាការពិចារណានិងសម្រេច។

៣.ដើមចោទប្តឹងទាមទារអត្រាការប្រាក់ ចំនួន ៩៧៤ (ប្រាំបួនរយចិតសិបបួន)ដុល្លារអាមេរិក ក្នុង ១ ខែ ដោយផ្អែកលើកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ នៃប្រាក់ដើមចំនួន ៥៥.៦៥០.០០០ (ហាសិបប្រាំលានប្រាំមួយសែនប្រាំម៉ឺន)រៀល ពីសហចុងចម្លើយ គិតចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៨ ដល់ថ្ងៃសងគ្រប់ចំនួន។ ឃើញថា: ការទាមទាររបស់ដើមចោទនេះ មិនត្រឹមត្រូវតាមច្បាប់នោះទេ តាមបញ្ញត្តិមាត្រា ១៧ នៃច្បាប់ស្តីការអនុវត្តក្រមរដ្ឋប្បវេណី និងប្រការ ១ នៃប្រកាសស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិតលេខ ១២៨ កយប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ បានកំណត់អត្រាការប្រាក់ត្រឹមតែ ១៨(ដប់ប្រាំបី)ភាគរយក្នុងមួយឆ្នាំ គប្បីតុលាការពិចារណាទៅតាមច្បាប់។

៤.ដើមចោទប្តឹងទាមទារសងសំណងការខូចខាតលើសេវាកម្មច្បាប់ និងជំងឺចិត្ត គិតជាប្រាក់ចំនួន ២០.០០០.០០០ (ម្ភៃលាន)រៀល ពីសហចុងចម្លើយ ឃើញថា ការទាមទារនេះមិនមានមូលហេតុសមរម្យដែលអាចឱ្យតុលាការជឿជាក់បានទេ គប្បីតុលាការពិចារណាសម្រេចតាមស្ថានភាពជាក់ស្តែង។

៥.ដើមចោទប្តឹងសុំឱ្យតុលាការប្រកាសសាលក្រមនេះ មានអានុភាពអនុវត្តជាបណ្តោះអាសន្នបានលើប្រាក់ដើម ចំនួន ៥៥.៦៥០.០០០(ហាសិបប្រាំលានប្រាំមួយសែនប្រាំម៉ឺន)រៀល ឃើញថា ការប្តឹងសុំនេះ មិនមានហេតុផលសមរម្យនោះទេ ម្យ៉ាងទៀតដោយសារតែសហចុងចម្លើយ នៅតែបដិសេធចំនួនទឹកប្រាក់ដែលខ្លួនបានខ្ចី លើសពីនេះទៅទៀតនៅក្នុងសំណុំរឿងក៏មិនមានលិខិតប្រគល់ទទួលប្រាក់ នោះដែរគប្បីតុលាការប្រានចោលការទាមទារនេះ។

៦.ប្រាក់ប្រដាប់ក្តីតុលាការសម្រេចតាមបញ្ញត្តិមាត្រា ៦៤ និងមាត្រា ១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

## សេចក្តីសម្រេចបញ្ចប់

១.បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ[redacted]សម្បត្តិ និងប្រពន្ធឈ្មោះ [redacted]រីណា រួមគ្នាសងប្រាក់ដើមចំនួន ៥៥.៦៥០.០០០(ហាសិបប្រាំលានប្រាំមួយសែនប្រាំម៉ឺន)រៀល ឱ្យទៅដើមចោទឈ្មោះ[redacted]ថារឿន។

២.បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ[redacted]សម្បត្តិ និងប្រពន្ធឈ្មោះ [redacted]រីណា រួមគ្នាសងការប្រាក់ចំនួន ១៨(ដប់ប្រាំបី)ភាគរយ ក្នុង១(មួយ)ឆ្នាំ លើប្រាក់ដើមចំនួន ៥៥.៦៥០.០០០(ហាសិបប្រាំលានប្រាំមួយសែនប្រាំម៉ឺន)រៀល គិតពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ ទៅឱ្យដើមចោទឈ្មោះ [redacted]ថារឿន ការទាមទារលើសពីនេះត្រូវប្រានចោល។

៣.បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ[redacted]សម្បត្តិ និងប្រពន្ធឈ្មោះ[redacted]រីណា សងសំណងការខូចខាតលើសេវាកម្មច្បាប់ និងជំងឺចិត្ត គិតជាប្រាក់ចំនួន ២.០០០.០០០(ពីរលាន)រៀល ឱ្យទៅដើមចោទឈ្មោះ [redacted]ថារឿន ការទាមទារលើសពីនេះត្រូវប្រានចោល។



Scanned with CamScanner

៤.ច្រានចោលការទារទាមរបស់ដើមចោទឈ្មោះ [redacted] ថារឿន សុំអនុវត្តសាលក្រមជាបណ្ដោះអាសន្នលើប្រាក់ដើម ចំនួន ៥៥.៦៥០.០០០ (ហាសិបប្រាំលានប្រាំមួយសែនប្រាំម៉ឺន)រៀល។

៥. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ។

សាលក្រមនេះប្រកាសជាសាធារណៈនៅថ្ងៃចន្ទ ៩កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ ចំពោះមុខដើមចោទឈ្មោះ [redacted] ថារឿន និងចំពោះមុខសហចុងចម្លើយឈ្មោះ [redacted] សម្បត្តិ និងប្រពន្ធឈ្មោះ [redacted] រ៉ែណា។

**ទុកសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។**

ថ្ងៃចន្ទ ៩កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
ធ្វើនៅតាកែវ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣
**ចៅក្រម**

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃចន្ទ ៩កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
ធ្វើនៅតាកែវ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣

បានឃើញ
**ចៅក្រម**
[redacted]

**ក្រឡាបញ្ជី**
[redacted]



Scanned with CamScanner